**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តបន្ទាយមានជ័យ**
លេខ:...២០១/២០.........ស.រ.ណ

ថ្ងៃចន្ទ ១៤រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
បន្ទាយមានជ័យ ថ្ងៃទី ២៣ ខែមីនា ឆ្នាំ ២០២០

# សេចក្ដីជូនដំណឹង

រដ្ឋបាលខេត្តបន្ទាយមានជ័យ សូមជម្រាបជូនដំណឹងដល់សាធារណជន ពិសេសបងប្អូនប្រជាពលរដ្ឋទាំងអស់ដែលទើបអញ្ជើញត្រលប់មកពីធ្វើការនៅព្រះរាជាណាចក្រថៃ និងពីបណ្ដាប្រទេសមួយចំនួនទៀតឲ្យបានជ្រាបថា មេរោគកូវីដ១៩ (COVID-19) បាន និងកំពុងរាតត្បាតនៅទូទាំងពិភពលោក ដោយឡែកនៅព្រះរាជាណាចក្រកម្ពុជា ក្រសួងសុខាភិបាលបានរកឃើញអ្នកមានផ្ទុកមេរោគកូវីដ១៩(COVID-19) ចំនួន៨៦ករណី គិតត្រឹមថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០ ដោយមេរោគនេះកំពុងតែបន្តរីករាលដាលជាបន្តបន្ទាប់។

ដើម្បីចូលរួមទប់ស្កាត់ការរីករាលដាល និងការចម្លងមេរោគកូវីដ(COVID-19)នៅក្នុងខេត្តបន្ទាយមានជ័យ ក៏ដូចជាក្នុងព្រះរាជាណាចក្រកម្ពុជា រដ្ឋបាលខេត្ត ស្នើបងប្អូនប្រជាពលរដ្ឋទាំងអស់ដែលទើបអញ្ជើញត្រលប់មកពីធ្វើការនៅព្រះរាជាណាចក្រថៃ និងពីបណ្ដាប្រទេសមួយចំនួនទៀត ត្រូវអនុវត្តតាមការណែនាំដូចខាងក្រោម ៖

១-ត្រូវជូនដំណឹងទៅរដ្ឋបាលក្រុង ស្រុកទាំង៩ ដូចមានតារាងលេខទូរស័ព្ទសម្រាប់ទំនាក់ទំនងដែលជាឯកសារឧបសម្ព័ន្ធ។

២-ត្រូវដាក់ខ្លួនឲ្យនៅដាច់ដោយឡែករយៈពេល១៤ថ្ងៃ ដោយអនុវត្តតាមសេចក្ដីណែនាំរបស់ក្រសួងសុខាភិបាល។ ក្នុងករណីដែលបងប្អូនមានការលំបាក ក្នុងការអនុវត្តសេចក្ដីណែនាំរបស់ក្រសួងសុខាភិបាល ត្រូវរាយការណ៍ទៅអាជ្ញាធរមូលដ្ឋាន ដើម្បីមានមូលដ្ឋានដោះស្រាយបញ្ហាជូន។

៣-ក្នុងករណីដែលបងប្អូនមានអាការៈមួយចំនួន ដូចជា ក្អក ឡើងកម្ដៅ៣៨អង្សាសេ ពិបាកដកដង្ហើម ដែលសង្ស័យថាអាចមានផ្ទុកមេរោគកូវីដ១៩(COVID-19) សូមបងប្អូនទំនាក់ទំនងតាមរយៈលេខទូរស័ព្ទដូចមានឯកសារឧបសម្ព័ន្ធភ្ជាប់មកជាមួយ ឬអាចទំនាក់ទំនងដោយផ្ទាល់ទៅអាជ្ញាធរភូមិ ប៉ុស្ដិ៍នគរបាលឃុំ សង្កាត់ និងរដ្ឋបាលឃុំ សង្កាត់ និងមន្ទីរពេទ្យរដ្ឋដែលនៅជិតទីកន្លែងរស់នៅរបស់បងប្អូនជាបន្ទាន់។

៤-អាជ្ញាធរភូមិ ប៉ុស្ដិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ និងរដ្ឋបាលឃុំ សង្កាត់ ត្រូវធ្វើការរាយការណ៍ជាបន្ទាន់ ក្នុងករណីដែលទទួលបានព័ត៌មានថាមានបងប្អូនប្រជាពលរដ្ឋដែលទើបអញ្ជើញត្រលប់មកពីធ្វើការនៅព្រះរាជាណាចក្រថៃ និងពីបណ្ដាប្រទេសមួយចំនួនទៀតទៅរដ្ឋបាលក្រុង ស្រុក ដើម្បី

អាសយដ្ឋាន: ផ្លូវជាតិលេខ៥ សង្កាត់អូរអំបិល ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ទូរស័ព្ទ-ទូរសារ (Phone-Fax) ០៥៤ ៧១០០៦២ Email: banteaymeanchey1@gmail.com ,
Web: www.bmc.ncdd.gov.kh , www.facebook.com/adminbmcs , Telegram: 012 673086 / 092 947310

# លេខទូរស័ព្ទរដ្ឋបាលក្រុង ស្រុកទាំង៩ សំរាប់ទំនាក់ទំនង

| ល.រ | រដ្ឋបាលក្រុង ស្រុក | តួនាទី | ឈ្មោះអ្នកទំនាក់ទំនង | លេខទូរស័ព្ទ |
|---|---|---|---|---|
| ១ | មង្គលបូរី | អភិបាល | លោក ផ្ទើ ដាស៊ីណង់ | 012500063 |
| | | អភិបាលរង | លោក ពិន សេងហាប់ | 012420396 |
| | | នាយករដ្ឋបាល | លោក មិន និមល | 077234848 |
| | | ប្រធានការិ. សង្គមកិច្ច និងសុខុមាលភាពសង្គម | លោក ម៉ក់ កៀយ | 012695994 |
| ២ | ភ្នំស្រុក | អភិបាល | លោក យឹម សំណាង | 099585899 |
| | | អភិបាលរង | លោក សំរិទ្ធ អប់ | 077417651 |
| | | នាយករដ្ឋបាល | លោក ប៉ៅ អ៊ឹង | 077952360 |
| | | ប្រធានការិ. សង្គមកិច្ច និងសុខុមាលភាពសង្គម | លោក ព្រឿង ប៊ុនរ៉ែក | 092218662 |
| ៣ | ព្រះនេត្រព្រះ | អភិបាល | លោក ឃុ ពៅ | 012444476 |
| | | អភិបាលរង | លោក យឹម យឿន | 0926333362 |
| | | អភិបាលរង | លោក ប៊ុន លាងផេង | 092635181 |
| | | នាយករដ្ឋបាល | លោក ហ៊ឹង សុជា | 092443502 |
| | | ប្រធានការិ. សង្គមកិច្ច និងសុខុមាលភាពសង្គម | លោក តាន់ ជួយ | 012565750 |
| ៤ | សិរីសោភ័ណ | អភិបាល | លោក ហ៊ីល រ៉ាយ៉ា | 061 899799<br>081700009 |
| | | អភិបាលរង | លោក ម៉ៅ វណ្ណា | 089228889 |
| | | អភិបាលរង | លោក ផន ផាវុធ | 011717971 |
| | | នាយករដ្ឋបាល | លោក រី រ៉ា | 012282074 |
| | | ប្រធានការិ. សង្គមកិច្ច និងសុខុមាលភាពសង្គម | លោកស្រី តែ គឹមហ៊ាប | 012 48 01 19 |
| ៥ | អូរជ្រៅ | អភិបាល | លោក លី សុវណ្ណារិទ្ធ | 012560606 |
| | | អភិបាលរង | លោក អាន វណ្ណៈ | 012918392<br>0979000200 |
| | | នាយករដ្ឋបាល | លោក ហឿន ចាន់ថន | 011558166<br>0897767760 |
| | | ប្រធានការិ. សង្គមកិច្ច និងសុខុមាលភាពសង្គម | លោកស្រី ឈួន កាន់យ៉ា | 092257443 |

វិធានការបង្ការ និងទប់ស្កាត់ការរាលដាលនៃមេរោគកូវីដ១៩(COVID-19) និងត្រូវចុះអប់រំ ណែនាំដល់បងប្អូនប្រជាពលរដ្ឋទាំងអស់នោះអំពីការដាក់ខ្លួនឲ្យនៅដាច់ដោយឡែករយៈពេល១៤ថ្ងៃ។

រដ្ឋបាលខេត្តបន្ទាយមានជ័យ មានសង្ឃឹមយ៉ាងមុតមាំថា បងប្អូនប្រជាពលរដ្ឋទាំងអស់ដែលទើបអញ្ជើញត្រលប់មកពីធ្វើការនៅព្រះរាជាណាចក្រថៃ និងពីបណ្តាប្រទេសមួយចំនួនទៀត ត្រូវចូលរួមទប់ស្កាត់ការរីករាលដាលមេរោគកូវីដ១៩(COVID-19)នេះ ដើម្បីសេចក្តីសុខក្រុមគ្រួសារ ជាទីស្រឡាញ់ សាច់ញាតិក៏ដូចសង្គមជាតិយើងផងដែរ។

ទទួលបានសេចក្តីជូនដំណឹងនេះ ស្នងការដ្ឋាននគរបាលខេត្ត បញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្ត បញ្ជាការដ្ឋានតំបន់ប្រតិបត្តិការសឹករងខេត្ត កងកម្លាំងប្រដាប់អាវុធ រដ្ឋបាលក្រុង ស្រុក ទាំង៩ មន្ទីរ អង្គភាពជំនាញពាក់ព័ន្ធ និងបងប្អូនប្រជាពលរដ្ឋទាំងអស់ ត្រូវចូលរួមសហការអនុវត្តសេចក្តីជូនដំណឹងនេះ ឲ្យទទួលបានលទ្ធផលល្អប្រសើរ និងប្រកបដោយប្រសិទ្ធភាពខ្ពស់។

អភិបាលខេត្ត

អ៊ុំ រាត្រី

**<u>ចម្លងជូន</u>** ÷
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងសុខាភិបាល
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រុមប្រឹក្សាខេត្ត
  "ដើម្បីគោរពជូនជ្រាប"
- គ្រប់កងកំលាំងប្រដាប់អាវុធឈរជើងក្នុងខេត្ត
- ស្នងការដ្ឋាននគរបាលខេត្ត
- បញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្ត
- បញ្ជាការដ្ឋានតំបន់ប្រតិបត្តិការសឹករងខេត្ត
- សាលាក្រុង ស្រុក
- មន្ទីរសុខាភិបាលខេត្ត
- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត
- មន្ទីរព័ត៌មានខេត្ត
  "ដើម្បីមុខការ"
- គ្រប់ប្រព័ន្ធផ្សព្វផ្សាយ
  "ដើម្បីជួយផ្សព្វផ្សាយ"
- ឯកសារ កាលប្បវត្តិ

អាសយដ្ឋានៈ ផ្លូវជាតិលេខ៥ សង្កាត់អូរអំបិល ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ទូរស័ព្ទ-ទូរសារ
(Phone-Fax) ០៥៤ ៧១០០៦២ Email: banteaymeanchey1@gmail.com ,
Web: www.bmc.ncdd.gov.kh , www.facebook.com/adminbmcs , Telegram: 012 673086 / 092 947310

| | | | | |
|---|---|---|---|---|
| ៦ | ស្វាយចេក | អភិបាល | លោក លឿង សុភក្តិ | 012516767 |
| | | អភិបាលរង | លោក ស៊ុត ង៉ុយ | 012424649 |
| | | នាយករដ្ឋបាល | លោក ខែន រិទ្ធី | 017317417 |
| | | ប្រធានការិ. សង្គមកិច្ច និងសុខុមាលភាពសង្គម | លោក ចាន់ ឆេក្ | 012636912 |
| ៧ | ថ្មពួក | អភិបាល | លោក ឡេប ឈួន | 012565413 |
| | | អភិបាលរង | លោក យង់ យ៉ន | 012284291 |
| | | នាយករដ្ឋបាល | លោក ឈឿយ ជឿម | 092581967 |
| | | ប្រធានការិ. សង្គមកិច្ច និងសុខុមាលភាពសង្គម | លោក អំ សំរេច | 089778898 |
| ៨ | ម៉ាឡៃ | អភិបាល | លោក អែម សុខា | 012543844 |
| | | អភិបាលរង | លោក ស្វាយ ជា | 078393962 |
| | | នាយករដ្ឋបាល | លោក អេង សាម៉ុន | 012443187<br>0976000893 |
| | | ប្រធានការិ. សង្គមកិច្ច និងសុខុមាលភាពសង្គម | លោក គង់ ប៊ុនសឿម | 012572415 |
| ៩ | ប៉ោយប៉ែត | អភិបាល | លោក គាត ហ៊ុល | 012983856<br>0977983856 |
| | | អភិបាលរង | លោក ហឿន វិរៈ | 095639997<br>0882898168 |
| | | នាយករដ្ឋបាល | លោក ញឹម ធឿង | 012902414 |
| | | ប្រធានការិ. សង្គមកិច្ច និងសុខុមាលភាពសង្គម | លោក គង់ វណ្ណៈ | 012832462 |